ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.១១៧៤៧.សហវ.ប្រក

# ប្រកាស
# ស្ដីពី
# ភាគទូកិច្ចសារពើពន្ធ
# ចំពោះសហគ្រាសដែលអនុវត្តពហុគម្រោង

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា1
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់ក្នុងការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់កាតព្វកិច្ចសារពើពន្ធ ចំពោះសហគ្រាសនីតិបុគ្គលណាមួយ ដែលអនុវត្តពហុគម្រោង (សកម្មភាពអាជីវកម្មច្រើន) ហើយទទួលបានរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខុសៗគ្នា និង/ឬជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ស្របតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីវិនិយោគ។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពចំពោះសហគ្រាសនីតិបុគ្គលណាមួយ ដែលអនុវត្ត÷

- ពហុគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ)
- ពហុគម្រោងមិនមែន គ.ល.គ ដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា
- គម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង។

ប្រកាសនេះមិនត្រូវអនុវត្តចំពោះ÷

- ពហុគម្រោង គ.ល.គ ដែលទទួលបានរយៈពេលចាប់ផ្តើម និងបញ្ចប់ការលើកលែងពន្ធលើប្រាក់ចំណេញដូចគ្នា និងជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា
- ពហុគម្រោងមិនមែន គ.ល.គ ដែលត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា
- ពហុគម្រោងដែលចុះបញ្ជីពន្ធដារជាសហគ្រាសនីតិបុគ្គលផ្សេងៗគ្នា។

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ÷

១- "ពហុគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហៅកាត់ ពហុគម្រោង គ.ល.គ" សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់លើសពីមួយឡើងទៅ ទទួលបានរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខុសៗគ្នា ឬជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា អនុវត្តដោយសហគ្រាសនីតិបុគ្គលណាមួយ។

២- "ពហុគម្រោងមិនមែន គ.ល.គ" សំដៅដល់សកម្មភាពអាជីវកម្មច្រើនដែលមិនមែនជាគម្រោង គ.ល.គ។

៣- "ចំណូលបន្ទាប់បន្សំរបស់សហគ្រាស" មិនត្រូវបានចាត់ទុកថាជាគម្រោងដោយឡែករបស់សហគ្រាសឡើយ។ ចំណូលបន្ទាប់បន្សំមានជាអាទិ៍ ចំណូលពីអចលនទ្រព្យ ចំណូលពីមូលបត្រ និងភាគហ៊ុន ចំណូលពីឥណទេយ្យ ប្រាក់ធានា គណនីសន្សំ គណនីចរន្ត ស្ហយសារ ចំណូលពីភាគលាភ អំណោយនិងឧបត្ថម្ភកធន និងចំណូលបន្ទាប់បន្សំប្រហាក់ប្រហែលដទៃទៀត ដូចមានចែងក្នុងផ្នែក ៤.៩ និងផ្នែក ៤.១០ នៃប្រកាសលេខ ១០៥៩ សហវ. ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ។

**ប្រការ ៤.- ការចុះបញ្ជី និងការផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធ**

ដូចមានចែងក្នុងមាត្រា៣ ថ្មី និងមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងមាត្រា៥.៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលដៅពន្ធដារ÷

១- សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងត្រូវបានផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធដោយឡែកៗពីគ្នា។

២- គម្រោង គ.ល.គ នីមួយៗ ឬគម្រោងមិនមែន គ.ល.គ នីមួយៗ ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធមួយដោយឡែកៗពីគ្នា។

**ប្រការ ៥.- ភារកិច្ចសារពើពន្ធ និងកិច្ចបញ្ជិកាគណនេយ្យរបស់សហគ្រាស**

សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការ៤ ខាងលើ ត្រូវ÷

១- ស្នើសុំចុះបញ្ជី និងប្រកាសបង់ពន្ធប៉ាតង់សម្រាប់គម្រោងនីមួយៗនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយគម្រោងនីមួយៗធ្វើសកម្មភាពសេដ្ឋកិច្ច។

២- ញែកដាច់ពីគ្នាដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក-កម្មករ អ្នកគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុផ្សេងៗសម្រាប់បម្រើឱ្យគម្រោងនីមួយៗ។

៣- កាន់កាប់និងកត់ត្រាបញ្ជិកាគណនេយ្យ និងត្រូវបែងចែកឱ្យបានត្រឹមត្រូវនូវចំណូល និងចំណាយ ដែលកើតឡើងដោយឡែកៗពីគ្នាសម្រាប់គម្រោងនីមួយៗ។

៤- ចំពោះចំណូល និងចំណាយដែលមិនអាចបែងចែកដាច់ដោយឡែកពីគ្នាតាមគម្រោងនីមួយៗ សហគ្រាសត្រូវធ្វើការបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោលធៀបនឹងចំណាយ។ ក្នុងករណីទាក់ទិននឹងគម្រោងដែលមិនទាន់មានផលរបរ សហគ្រាសត្រូវបែងចែកតាមសមាមាត្រទំហំនៃការប្រើប្រាស់ទ្រព្យសកម្ម ឬទំហំនៃចំណាយទាំងនោះ។ ចំណាយសមាមាត្រទាំងនោះ រួមមាន ចំណាយរដ្ឋបាលរួម ចំណាយជួលការិយាល័យរួម ប្រាក់បៀវត្សអ្នកគ្រប់គ្រង ឬបុគ្គលិកទទួលខុសត្រូវរួម និងចំណាយផ្សេងៗទៀតសម្រាប់បំរើសកម្មភាពច្រើនជាងមួយគម្រោង។

៥- កាន់កាប់ កត់ត្រា និងរក្សាបញ្ជីស្តុកទំនិញ ផលិតផលសម្រេច ផលិតផលពាក់កណ្តាលសម្រេច វត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗគ្នាសម្រាប់គម្រោងនីមួយៗដាច់ដោយឡែកពីគ្នា។

៦- ចំពោះទ្រព្យសកម្មរយៈពេលវែងដែលមិនអាចធ្វើការបែងចែកបាន ហើយត្រូវបានប្រើប្រាស់លាយឡំគ្នា សហគ្រាសត្រូវកត់ត្រាតាមដាន និងធ្វើវិលស់នៃទ្រព្យទាំងនោះនៅក្នុងគម្រោងដែលទ្រព្យសកម្មនោះត្រូវបានកត់ត្រាដំបូង ហើយត្រូវធ្វើការបែងចែកចំណាយទាយជ្ជទាន

ឱ្យដល់រំលស់នៃទ្រព្យទាំងនោះទៅតាមសមាមាត្រនៃផលរបរ ឬទំហំនៃការប្រើប្រាស់ ក្នុងករណីទាក់ទិនទៅនឹងគម្រោងដែលមិនទាន់មានផលរបរ។

៧- ធ្វើការកត់ត្រា និងគណនាការកាត់កង ចំពោះការយោងការខាតបង់ដែលសម្រេចបានក្នុងឆ្នាំកន្លងមកដាច់ដោយឡែកពីគ្នាសម្រាប់គម្រោងនីមួយៗ។

៨- កត់ត្រាចំណូលបន្ទាប់បន្សំ និងចំណាយបន្ទាប់បន្សំ សម្រាប់គម្រោងនីមួយៗ ដូចខាងក្រោម÷

ក- ត្រូវបែងចែកចំណូលបន្ទាប់បន្សំ ទៅតាមគម្រោងនីមួយៗដែលបង្កើតប្រភពចំណូលបន្ទាប់បន្សំទាំងនោះ ឬបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោល។ ក្នុងករណីមិនអាចបែងចែកបាន ត្រូវកត់ត្រាចំណូលបន្ទាប់បន្សំទាំងនោះក្នុងគម្រោងមួយណាដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខ្ពស់ជាងគេ ឬផុតរយៈពេលលើកលែងពន្ធមុនគេ។

ខ- ត្រូវបែងចែកចំណាយបន្ទាប់បន្សំ ទៅតាមគម្រោងនីមួយៗដែលបង្កើតប្រភពចំណាយបន្ទាប់បន្សំទាំងនោះ ឬបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោល។ ក្នុងករណីមិនអាចបែងចែកបាន ត្រូវកត់ត្រាចំណាយទាំងនោះក្នុងគម្រោងមួយណាដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាទាបជាងគេ ឬផុតរយៈពេលលើកលែងពន្ធក្រោយគេ។

**ប្រការ ៦.- ភាតព្វកិច្ចអាករលើតម្លៃបន្ថែម**

សហគ្រាសដូចមានចែងក្នុងប្រការ៤ ខាងលើ ដែលធ្វើការទិញ ឬផ្គត់ផ្គង់ជាប់អាករ ដូចមានចែងក្នុងជំពូក៣ នៃបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវ÷

១- ប្រើប្រាស់លេខអត្តសញ្ញាណកម្មសារពើពន្ធនីមួយៗដោយឡែកពីគ្នា សម្រាប់ការនាំចូល-នាំចេញ ការទិញទំនិញនិងសេវាក្នុងស្រុក សម្រាប់ធ្វើការផ្គត់ផ្គង់ទំនិញនិងសេវាឱ្យអតិថិជន។

២- រៀបចំទិនានុប្បវត្តិទិញ-លក់ដាច់ដោយឡែកពីគ្នាសម្រាប់គម្រោងនីមួយៗ និងកត់ត្រាតាមដានឥណទានអាករលើធាតុចូលនិងអាករលើធាតុចេញសម្រាប់គម្រោងនីមួយៗដោយឡែកពីគ្នា។

៣- ចំពោះឥណទានអាករលើធាតុចូលលើការទិញទ្រព្យសកម្មរយៈពេលវែង ដែលមិនអាចបែងចែកបាន ហើយត្រូវបានប្រើប្រាស់លាយឡំគ្នារវាងពហុគម្រោង គ.ល.គ ឬអនុវត្តពហុគម្រោងដែលជាគម្រោង គ.ល.គ ផងនិងមិនមែន គ.ល.គ ផង ឬអនុវត្តពហុគម្រោងមិនមែន គ.ល.គ សហគ្រាសត្រូវកត់ត្រាឥណទាននៃទ្រព្យទាំងនោះ ក្នុងគម្រោងដែលទ្រព្យសកម្មទាំងនោះ ត្រូវបានប្រើប្រាស់ដំបូង។

៤- ចំពោះឥណទានយោងនៅសល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលមិនអាចបែងចែកដាច់ដោយឡែកពីគ្នាតាមគម្រោងនីមួយៗ សហគ្រាសត្រូវធ្វើការបែងចែកតាមគោលការណ៍សមាមាត្រ ដោយយកផលរបរជាគោល។ ក្នុងករណីទាក់ទិនទៅនឹងគម្រោងដែលមិនទាន់មានផលរបរ សហគ្រាសត្រូវបែងចែកតាមសមាមាត្រទំហំនៃការប្រើប្រាស់ទ្រព្យសកម្ម ឬទំហំនៃចំណាយទាំងនោះ។ ដោយឡែកចំពោះឥណទានយោងនៅសល់ចាប់ពីថ្ងៃទី០១ ខែមករា

ឆ្នាំ២០១៦ រហូតដល់ប្រកាសនេះចូលជាធរមាន សហគ្រាសត្រូវញែកឥណទានយោងនៅសល់ទាំងនោះ តាមគម្រោងនីមួយៗ និងត្រូវធ្វើការកែតម្រូវលិខិតប្រកាសអាករលើតម្លៃបន្ថែមប្រចាំខែនីមួយៗ។

**ប្រការ ៧.- ការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ**

សហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោង គ.ល.គ ឬអនុវត្តគម្រោង គ.ល.គ ផង និងមិនមែន គ.ល.គ ផង ឬពហុគម្រោងមិនមែន គ.ល.គ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ តាមគម្រោងនីមួយៗដាច់ដោយឡែកពីគ្នា ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៨.- ពហុគម្រោងមិនមែន គ.ល.គ ជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា**

ចំពោះសហគ្រាសនីតិបុគ្គលណាមួយដែលអនុវត្តពហុគម្រោងមិនមែន គ.ល.គ ត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាដូចគ្នា ទោះបីមានសកម្មភាពអាជីកម្មច្រើនក៏ដោយ ត្រូវបំពេញកាតព្វកិច្ចសារពើពន្ធបញ្ចូលគ្នាតែមួយដូចជា ការចុះបញ្ជីនិងលេខអត្តសញ្ញាណកម្មសារពើពន្ធ ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យ និងដាក់លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ព្រមទាំងកាតព្វកិច្ចសារពើពន្ធដទៃទៀត តាមបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៩.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៦

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ